ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

លេខ......០៥៩........អ.ស.ហ.ប្រ.ក

# ប្រកាស
# ស្តីពី
# លក្ខខណ្ឌ និងនីតិវិធីនៃការផ្តល់អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគា
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង
- យោងតាមតម្រូវការចាំបាច់របស់និយ័តករធានារ៉ាប់រងកម្ពុជា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ ._**

ប្រកាសនេះមានគោលបំណងកំណត់លក្ខខណ្ឌនិងនីតិវិធីក្នុងការផ្តល់និងការបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងសកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង និងសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់សកម្មភាពអាជីវកម្មភ្នាក់ងារធានារ៉ាប់រង និងជើងសាធានារ៉ាប់រងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

វាក្យសព្ទដែលប្រើប្រាស់ក្នុងប្រកាសនេះ មាននិយមន័យដូចតទៅៈ

- **ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង** សំដៅដល់នីតិបុគ្គលដែលជួសមុខឱ្យក្រុមហ៊ុនធានារ៉ាប់រងធ្វើការណែនាំអំពីការលក់បណ្ណសន្យារ៉ាប់រង ការរៀបចំកិច្ចសន្យាធានារ៉ាប់រង ការប្រមូលបុព្វលាភ ការរៀបចំការធ្វើសំណងជាដើម ក្នុងក្របខណ្ឌកំណត់ច្បាស់លាស់នៃកិច្ចព្រមព្រៀងរវាងភ្នាក់ងារធានារ៉ាប់រងនិងក្រុមហ៊ុនធានារ៉ាប់រង ដោយទទួលកម្រៃជើងសាពីក្រុមហ៊ុនធានារ៉ាប់រងនោះ ទាំងម៉ូឌែលណែនាំអតិថិជនឬម៉ូឌែលភ្នាក់ងារ។
- **ក្រុមហ៊ុនជើងសាធានារ៉ាប់រង** សំដៅដល់នីតិបុគ្គលដែលធ្វើការក្នុងគោលដៅនៃអត្ថប្រយោជន៍របស់អ្នកត្រូវបានធានារ៉ាប់រង ផ្តល់សេវាប្រឹក្សា ផ្តល់ព័ត៌មានទាក់ទងនឹងប្រភេទធានារ៉ាប់រង លក្ខខណ្ឌ និងបុព្វលាភនៃកិច្ចសន្យាធានារ៉ាប់រង ធ្វើការចរចា និងរៀបចំកិច្ចសន្យាធានារ៉ាប់រងរវាងអ្នកស្នើសុំការធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រង និងលក់បណ្ណសន្យារ៉ាប់រង ដោយទទួលកម្រៃជើងសាពីក្រុមហ៊ុនធានារ៉ាប់រង និង/ឬកម្រៃប្រឹក្សាពីអតិថិជន។
- ***សាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស*** សំដៅដល់សាខារបស់ក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃហើយមានទីតាំងធ្វើពាណិជ្ជកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា។ សាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស គឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ។

- **នីតិបុគ្គលប្រតិស្រុត** សំដៅដល់នីតិបុគ្គលដែលបានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។
- **អគ្គនាយក** សំដៅដល់បុគ្គលមានឋានៈខ្ពស់បំផុតក្នុងកម្រិតប្រតិបត្តិរបស់ក្រុមហ៊ុន ដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាភិបាល ដើម្បីគ្រប់គ្រងកិច្ចប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន។
- **បុគ្គលស្នើសុំ** សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលដាក់ពាក្យស្នើសុំសេវារដ្ឋបាលពីនិយ័តករធានារ៉ាប់រងកម្ពុជា។
- **ភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល** សំដៅដល់រូបវន្តបុគ្គលដែលបានចុះឈ្មោះក្នុងបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលតាមប្រព័ន្ធស្វ័យប្រវត្តកម្មរបស់និយ័តករធានារ៉ាប់រងកម្ពុជា ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច

**ប្រការ៤ .-**

និយ័តករធានារ៉ាប់រងកម្ពុជា ដែលសរសេរជាអក្សរកាត់ថា“**ន.ធ.ក.**” មានសមត្ថកិច្ចក្នុងការផ្តល់ និងការបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ឬជាក្រុមហ៊ុនជើងសាធានារ៉ាប់រងឬជាសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៣

## លក្ខខណ្ឌ និងនីតិវិធី

## នៃការផ្តល់ និងការបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង

### ផ្នែកទី១

### ការផ្តល់ និងការបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង

**ប្រការ៥ .-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រង ជាក្រុមហ៊ុន ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រងមក **ន.ធ.ក.** ដោយបំពេញលក្ខខណ្ឌគោលដូចខាងក្រោម៖

- ជានីតិបុគ្គលប្រតិស្រុត
- មានដើមទុនអប្បបរមាចំនួន ៨០ ០០០ ០០០ (ប៉ែតសិបលាន) រៀល ក្នុងនោះប្រាក់តម្កល់ធានាអាជីវកម្មមានចំនួន ៤០ ០០០ ០០០ (សែសិបលាន) រៀល
- មានបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងយ៉ាងតិច ១ (មួយ) រូប។

**ប្រការ៦ ._**

ជាដំណាក់កាលដំបូង មុននឹងស្នើសុំអាជ្ញាបណ្ណ បុគ្គលត្រូវស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រង ជាក្រុមហ៊ុន ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រងជាក្រុមហ៊ុន
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- ឯកសារបញ្ជាក់នាមករណ៍ក្រុមហ៊ុនបម្រុងទុក នៅក្រសួងពាណិជ្ជកម្ម
- ឯកសារអំពីការសិក្សាសមិទ្ធិលទ្ធភាពនៃទីផ្សារភ្នាក់ងារធានារ៉ាប់រងកម្ពុជា
- ផែនការអាជីវកម្មរយៈពេល ៣ (បី) ឆ្នាំ
- សេចក្តីព្រាងលក្ខន្តិកៈក្រុមហ៊ុនដែលនឹងបង្កើត
- ឯកសារថតចម្លងបញ្ជាក់អត្តសញ្ញាណរបស់ភាគទុនិកៈ
    - សម្រាប់ភាគទុនិកជារូបវន្តបុគ្គល ត្រូវផ្តល់អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន
    - សម្រាប់ភាគទុនិកជានីតិបុគ្គល ត្រូវផ្តល់ឯកសារគតិយុត្តអំពីអាជីវកម្ម និងអាសយដ្ឋានទីស្នាក់ការកណ្តាល
- ឯកសារថតចម្លងបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល និងអភិបាល រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន និងប្រវត្តិរូបសង្ខេបស្តីពីបទពិសោធការងារនិងការសិក្សាដោយភ្ជាប់សញ្ញាបត្រ ។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាតជាគោលការណ៍ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២៥ (ម្ភៃប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។ **ន.ធ.ក.** ផ្តល់លិខិតអនុញ្ញាតជាគោលការណ៍នេះ ជូនបុគ្គលស្នើសុំ សម្រាប់ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងបន្តនីតិវិធីផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ៧ ._**

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រង ជាក្រុមហ៊ុន និងបានចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- សាលាកប័ត្រព័ត៌មានក្រុមហ៊ុន ដែលបានបំពេញ និងមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល តាមទម្រង់ដែលកំណត់ដោយ **ន.ធ.ក.**

- លិខិតអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណ
- លក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារអំពីរចនាសម្ព័ន្ធ និងសមាសភាពគណៈគ្រប់គ្រង ដោយមានហត្ថលេខារបស់អគ្គនាយក និងមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារអំពីគណនីរបស់ក្រុមហ៊ុននៅធនាគារដែលបញ្ជាក់ចំនួនដើមទុនអប្បបរមាដែលមានចំនួន ៨០ ០០០ ០០០(ប៉ែតសិបលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារបញ្ជាក់ចំនួនប្រាក់តម្កល់ធានាអាជីវកម្មដែលមានចំនួន ៤០ ០០០ ០០០ (សែសិបលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បណ្ណពន្ធប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- កិច្ចសន្យាជួលទីតាំង ឬបណ្ណកម្មសិទ្ធិ ជាច្បាប់ថតចម្លងដោយធ្វើនីត្យានុកូលកម្មពីអាជ្ញាធរដែនដី
- លិខិតតែងតាំងបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ ដោយភ្ជាប់ជាមួយនូវបណ្ណចុះបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុនបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាអគ្គនាយក រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន និងប្រវត្តិរូបសង្ខេបអំពីបទពិសោធការងារ និងការសិក្សាដោយភ្ជាប់សញ្ញាបត្រ
- លិខិតឬព្រឹត្តិបត្រថ្កោលទោស របស់បុគ្គលដែលត្រូវតែងតាំងជាអគ្គនាយក ជាច្បាប់ដើមឬថតចម្លងបញ្ជាក់ដោយសារការី។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់អាជ្ញាបណ្ណ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ៨** _

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ដែលមានបំណងប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រង ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង មក **ន.ធ.ក.**។ ជាដំណាក់កាល

ដំបូង មុននឹងស្នើសុំអាជ្ញាបណ្ណ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ត្រូវស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រងដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រង
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- ផែនការអាជីវកម្មរយៈពេល ៣ (បី) ឆ្នាំ
- លក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- លិខិតអនុញ្ញាតប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន (ប្រសិនបើមានការតម្រូវដោយនិយ័តករតាមវិស័យ ដូចជាប៉េងកាសួរេន ចេញដោយធនាគារជាតិនៃកម្ពុជា ជាដើម)។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាតជាគោលការណ៍ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២៥ (ម្ភៃប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។ **ន.ធ.ក.** ផ្តល់លិខិតអនុញ្ញាតជាគោលការណ៍នេះ ជូនបុគ្គលស្នើសុំសម្រាប់បន្តនីតិវិធីផ្សេងៗតាមការចាំបាច់។

**ប្រការ៩.-**

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រង គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រងដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- សាលាកប័ត្រព័ត៌មានក្រុមហ៊ុន ដែលបានបំពេញ និងមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល តាមទម្រង់ដែលកំណត់ដោយ **ន.ធ.ក.**
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណ
- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន អំពីអ្នកគ្រប់គ្រងដំណើរការលក់ផលិតផលធានារ៉ាប់រង រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន និងកិច្ចសន្យាការងារ
- ឯកសារបញ្ជាក់ចំនួនប្រាក់តម្កល់ធានាអាជីវកម្មដែលមានចំនួន ៤០ ០០០ ០០០ (សែសិបលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន

- លិខិតតែងតាំងបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ ដោយភ្ជាប់ជាមួយនូវបណ្ណចុះបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន ។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់អាជ្ញាបណ្ណ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ១០.-**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ត្រូវស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រងមក **ន.ធ.ក.** ឱ្យបានមុនរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ នៃកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនភ្នាក់ងារធានា-រ៉ាប់រងដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណ
- អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ដែលត្រូវបន្តសុពលភាព ជាច្បាប់ដើម
- ផែនការអាជីវកម្មសម្រាប់រយៈពេល ៣ (បី) ឆ្នាំបន្ទាប់ ដោយមានហត្ថលេខារបស់អគ្គនាយក និងមានប្រថាប់ត្រាក្រុមហ៊ុន
- បណ្ណពន្ធប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់ឆ្នាំចុងក្រោយ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចបន្តសុពលភាពអាជ្ញាបណ្ណ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ១១.-**

ក្នុងករណីក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង មិនបានស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្ម បន្ទាប់ពីកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងនោះត្រូវចាត់ទុកថាប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រងដោយគ្មានអាជ្ញាបណ្ណ។

**ប្រការ១២ .-**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ដែលទទួលបានអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង នៅក្នុងព្រះរាជាណាចក្រកម្ពុជា អាចស្នើសុំការអនុញ្ញាតដំណើរការអាជីវកម្មភ្នាក់ងារធានារ៉ាប់រងតាមសាខាក្នុងស្រុក មក **ន.ធ.ភ.** ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំការអនុញ្ញាតដំណើរការអាជីវកម្មភ្នាក់ងារធានារ៉ាប់រងតាមសាខាក្នុងស្រុក
- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន អំពីអ្នកគ្រប់គ្រងដំណើរការលក់ផលិតផលធានារ៉ាប់រងតាមសាខា រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែននិងកិច្ចសន្យាការងារ
- បញ្ជីឈ្មោះបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងដែលលក់ផលិតផលធានារ៉ាប់រងដោយមានបញ្ជាក់ទីតាំងសាខាដែលទទួលបន្ទុក និងភ្ជាប់ជាមួយនូវបណ្ណចុះបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល នៅ **ន.ធ.ភ.** ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- លិខិតអនុញ្ញាតឱ្យសាខាក្នុងស្រុកប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន(ប្រសិនបើមានការតម្រូវដោយនិយ័តករតាមវិស័យ ដូចជា បេឡាកាស្សរេនចេញដោយធនាគារជាតិនៃកម្ពុជា ជាដើម)។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ភ.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាតឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ១៣ .-**

អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង មានសុពលភាព ៣(បី) ឆ្នាំ។ អាជ្ញាបណ្ណនេះមិនអាចផ្ទេរ ឬលក់បានឡើយ។

## ផ្នែកទី២

## ការផ្តល់ និងការបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស

**ប្រការ១៤ .-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មជើងសាធានារ៉ាប់រង ជាក្រុមហ៊ុន ឬសាខាក្រុមហ៊ុនបរទេស អាចស្នើសុំអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង តាមប្រភេទណាមួយដូចខាងក្រោម៖

ក. អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនជើងសាធានារ៉ាប់រងទូទៅឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងទូទៅបរទេស ឬ

ខ. អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនជើងសាធានារ៉ាប់រងអាយុជីវិតឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងអាយុជីវិតបរទេស ឬ

គ. អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនជើងសាធានារ៉ាប់រងបន្ត ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបន្តបរទេស។

**ប្រការ១៥ .-**

បុគ្គលដែលមានបំណងប្រកបអាជីវកម្មជើងសាធានារ៉ាប់រងជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង មក **ន.ធ.ក.** ដោយបំពេញលក្ខខណ្ឌគោល ដូចខាងក្រោម៖

- ជានីតិបុគ្គលប្រតិស្រុត
- មានដើមទុនអប្បបរមាចំនួន ៤០០ ០០០ ០០០(បួនរយលាន) រៀល ក្នុងនោះប្រាក់តម្កល់ធានាអាជីវកម្មមានចំនួន ២០០ ០០០ ០០០(ពីររយលាន) រៀល
- មានការធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈជើងសាធានារ៉ាប់រងដែលមានចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ២ ០០០ ០០០ ០០០(ពីរប៊ីលាន) រៀល
- មានបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងយ៉ាងតិច ១ (មួយ) រូប។

**ប្រការ១៦ .-**

ជាដំណាក់កាលដំបូង មុននឹងស្នើសុំអាជ្ញាបណ្ណ បុគ្គលត្រូវស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មជើងសាធានារ៉ាប់រង ជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មជើងសាធានារ៉ាប់រង ជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- ឯកសារអំពីការសិក្សាសមិទ្ធិលទ្ធភាពនៃទីផ្សារជើងសាធានារ៉ាប់រងកម្ពុជា
- ផែនការអាជីវកម្មរយៈពេល ៥ (ប្រាំ) ឆ្នាំ
- សេចក្តីព្រាងលក្ខន្តិកៈក្រុមហ៊ុនដែលនឹងបង្កើត
- ឯកសារថតចម្លងបញ្ជាក់អត្តសញ្ញាណរបស់ភាគទុនិកៈ
    - សម្រាប់ភាគទុនិកជារូបវន្តបុគ្គល ត្រូវផ្តល់អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន

- សម្រាប់ភាគទុនិកជានីតិបុគ្គល ត្រូវផ្តល់ឯកសារគតិយុត្តអំពីអាជីវកម្ម និងអាសយដ្ឋានទីស្នាក់ការកណ្តាល

- ឯកសារថតចម្លងបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាប្រធានក្រុមប្រឹក្សាភិបាល និងអភិបាល រួមមាន អត្តសញ្ញាណប័ណ្ណឬលិខិតឆ្លងដែន និងប្រវត្តិរូបសង្ខេបស្តីពីបទពិសោធការងារ និងការសិក្សាដោយភ្ជាប់សញ្ញាបត្រ
- ឯកសារបញ្ជាក់នាមករណ៍ក្រុមហ៊ុនបម្រុងទុក នៅក្រសួងពាណិជ្ជកម្ម
- ក្នុងករណីជាបុត្រសម្ព័ន្ធក្រុមហ៊ុន ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ត្រូវផ្តល់ឯកសារបន្ថែមដូចខាងក្រោម៖
  - លិខិតអនុញ្ញាតរបស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដើមឱ្យប្រកបអាជីវកម្មជើងសាធានារ៉ាប់រងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាច្បាប់ថតចម្លងបញ្ជាក់ដោយសារការី
  - សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម អនុញ្ញាតឱ្យប្រកបអាជីវកម្មជើងសាធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
  - ឯកសារអំពីប្រវត្តិសង្ខេប និងរចនាសម្ព័ន្ធនៃក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
  - របាយការណ៍ហិរញ្ញវត្ថុឆ្នាំចុងក្រោយរបស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម ដែលបានធ្វើសវនកម្ម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
  - ឯកសារអំពីចំណាត់ថ្នាក់របស់ក្រុមហ៊ុនមេ ឬក្រុមហ៊ុនដើម ដោយមានការវាយតម្លៃរបស់ភ្នាក់ងារចាត់ថ្នាក់ដែលទទួលស្គាល់ជាអន្តរជាតិ (ប្រសិនបើមាន)
  - របាយការណ៍ស្តីពីលទ្ធផលត្រួតពិនិត្យចុងក្រោយរបស់និយ័តករនៃប្រទេសដើម ជាច្បាប់ថតចម្លង (ប្រសិនបើមាន)។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាតជាគោលការណ៍ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២៥ (ម្ភៃប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។ **ន.ធ.ក.** ផ្តល់លិខិតអនុញ្ញាតជាគោលការណ៍នេះ ជូនបុគ្គលស្នើសុំសម្រាប់ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម និងបន្តនីតិវិធីផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ១៧.-**

បន្ទាប់ពីទទួលបានការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មជើងសាធានារ៉ាប់រង ជាក្រុមហ៊ុនឬ

សាខាក្រុមហ៊ុនបរទេស និងបានចុះបញ្ជីពាណិជ្ជកម្មតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនត្រូវស្នើសុំអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនជើងសាធានារ៉ាប់រងឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- សាលាកប័ត្រព័ត៌មានក្រុមហ៊ុន ដែលបានបំពេញ និងមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល តាមទម្រង់ដែលកំណត់ដោយ **ន.ធ.ក.**
- លិខិតអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មជើងសាធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណ
- លក្ខន្តិកៈ និងវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារអំពីរចនាសម្ព័ន្ធ និងសមាសភាពគណៈគ្រប់គ្រង ដោយមានហត្ថលេខារបស់អគ្គនាយក និងមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារអំពីគោលការណ៍ក្រុមហ៊ុនស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដោយមានហត្ថលេខារបស់អគ្គនាយក និងមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារបញ្ជាក់ដើមទុនអប្បបរមាចំនួន ៤០០ ០០០ ០០០(បួនរយលាន) រៀល ជារបាយការណ៍គណនីរបស់ក្រុមហ៊ុននៅធនាគារ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- ឯកសារបញ្ជាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ២០០ ០០០ ០០០ (ពីររយលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈជើងសាធានារ៉ាប់រងចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ២ ០០០ ០០០ ០០០(ពីរប៊ីលាន) រៀល ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បណ្ណពន្ធប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- កិច្ចសន្យាជួលទីតាំង ឬបណ្ណកម្មសិទ្ធិ ជាច្បាប់ថតចម្លងដោយធ្វើនីត្យានុកូលកម្មពីអាជ្ញាធរដែនដី
- លិខិតតែងតាំងបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ ដោយភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិ រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន

ប្រវត្តិរូបសង្ខេបដោយមានបញ្ជាក់ពីបទពិសោធការងារនិងការសិក្សា និងវិញ្ញាបនបត្រ វិជ្ជាជីវៈជើងសាធានារ៉ាប់រង ឬលិខិតបញ្ជាក់អំពីបទពិសោធការងារជើងសាធានារ៉ាប់រង ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន

- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុនបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់បុគ្គលដែលត្រូវតែងតាំងជាអគ្គនាយក រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន និងប្រវត្តិរូបសង្ខេបដោយមានបញ្ជាក់ពីបទពិសោធការងារនិងការសិក្សាដោយភ្ជាប់សញ្ញាបត្រ
- លិខិតឬព្រឹត្តិបត្រថ្កោលទោស របស់បុគ្គលដែលត្រូវតែងតាំងជាអគ្គនាយក ជាច្បាប់ដើមឬថតចម្លងបញ្ជាក់ដោយសារការី។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់អាជ្ញាបណ្ណ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ១៨.-**

ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ត្រូវស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង មក **ន.ធ.ក.** ឱ្យបានមុនរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ នៃកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រងដោយមានហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលដែលទទួលសិទ្ធិប្រទានពីក្រុមប្រឹក្សាភិបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បង្កាន់ដៃបង់ប្រាក់កម្រៃអាជ្ញាបណ្ណ
- អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ដែលត្រូវបន្តសុពលភាព ជាច្បាប់ដើម
- ផែនការអាជីវកម្មសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំបន្ទាប់ ដោយមានហត្ថលេខារបស់អគ្គនាយក និងមានប្រថាប់ត្រាក្រុមហ៊ុន
- វិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈជើងសាធានារ៉ាប់រងចំនួនទឹកប្រាក់ធានារ៉ាប់រងសមមូលនឹង ២ ០០០ ០០០ ០០០(ពីរប៊ីលាន) រៀល ដែលនៅមានសុពលភាព ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បណ្ណពន្ធប៉ាតង់ ឬបង្កាន់ដៃបង់ប្រាក់ពន្ធប៉ាតង់ឆ្នាំចុងក្រោយ ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ឆ.ក.** មានសិទ្ធិសម្រេចបន្តសុពលភាពអាជ្ញាបណ្ណ ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ១៩ .-**

ក្នុងករណីក្រុមហ៊ុនជើងសាធានារ៉ាប់រងឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសមិនបានស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ បន្ទាប់ពីកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសនោះ ត្រូវចាត់ទុកថាប្រកបអាជីវកម្មជើងសាធានារ៉ាប់រងដោយគ្មានអាជ្ញាបណ្ណ។

**ប្រការ២០ .-**

អាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ជាក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសមានសុពលភាព ៥ (ប្រាំ) ឆ្នាំ។ អាជ្ញាបណ្ណនេះមិនអាចផ្ទេរ ឬលក់បានឡើយ។

**ប្រការ២១ .-**

ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ត្រូវបន្តសុពលភាពវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈជើងសាធានារ៉ាប់រង ឱ្យទាន់ពេលវេលាមុនផុតសុពលភាពវិញ្ញាបនបត្រ និងត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **ន.ឆ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទបន្តសុពលភាពវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈជើងសាធានារ៉ាប់រង។

## ជំពូកទី៤

## ការតម្រូវផ្សេងៗ

**ប្រការ២២ .-**

ក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ក្រោយពីកាលបរិច្ឆេទទទួលបានអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ឬលិខិតអនុញ្ញាតដំណើរការអាជីវកម្មភ្នាក់ងារធានារ៉ាប់រងតាមសាខាក្នុងស្រុក ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស មិនបានចាប់ផ្តើមប្រតិបត្តិការអាជីវកម្ម អាជ្ញាបណ្ណអាជីវកម្ម ឬលិខិតអនុញ្ញាតដំណើរការអាជីវកម្មតាមសាខាក្នុងស្រុករបស់ក្រុមហ៊ុន ឬសាខាក្រុមហ៊ុននោះ នឹងត្រូវអស់សុពលភាពដោយស្វ័យប្រវត្តិ លើកលែងតែមានការអនុញ្ញាត ពី **ន.ឆ.ក.**។

**ប្រការ២៣ .-**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រង

បរទេស មិនអាចផ្តល់សេវាភ្នាក់ងារធានារ៉ាប់រង ឬសេវាជើងសាធានារ៉ាប់រង ជូនក្រុមហ៊ុនធានារ៉ាប់រង ដែលមិនមានអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា បានឡើយ។

**ប្រការ២៤.-**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រង បរទេស ត្រូវស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ក.** ចំពោះការចាប់ដៃគូឬផ្លាស់ប្តូរដៃគូផ្តល់សេវាភ្នាក់ងារ ធានារ៉ាប់រង ឬជើងសាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រង ដោយភ្ជាប់ឯកសារតម្រូវតាមករណីដូច ខាងក្រោម៖

ក. ចំពោះការស្នើសុំការអនុញ្ញាតចាប់ដៃគូផ្តល់សេវាជាមួយក្រុមហ៊ុនធានារ៉ាប់រង

- លិខិតស្នើសុំការអនុញ្ញាតចាប់ដៃគូផ្តល់សេវា
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ជាច្បាប់ដើមឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- សេចក្តីព្រាងកិច្ចព្រមព្រៀងដៃគូផ្តល់សេវាជាមួយក្រុមហ៊ុនធានារ៉ាប់រង
- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន បញ្ជាក់អំពីគុណវុឌ្ឍិរបស់បុគ្គលវិជ្ជាជីវៈ លក់ផលិតផលធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រងជាដៃគូ រួមមាន បណ្ណចុះបញ្ជីភ្នាក់ងារ ធានារ៉ាប់រងជារូបវន្តបុគ្គល និងវិញ្ញាបនបត្របញ្ចប់ការសិក្សាវគ្គបណ្តុះបណ្តាលឯកទេស វិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងដៃគូ ។

ខ. ចំពោះការស្នើសុំការអនុញ្ញាតផ្លាស់ប្តូរដៃគូផ្តល់សេវាជាមួយក្រុមហ៊ុនធានារ៉ាប់រង

- លិខិតស្នើសុំការអនុញ្ញាតផ្លាស់ប្តូរដៃគូផ្តល់សេវា
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ជាច្បាប់ដើមឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- លិខិតបញ្ជាក់ការបញ្ឈប់ការចាប់ដៃគូផ្តល់សេវារវាងក្រុមហ៊ុនធានារ៉ាប់រង និងក្រុមហ៊ុន ភ្នាក់ងារធានារ៉ាប់រង ឬក្រុមហ៊ុនជើងសាធានារ៉ាប់រងឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រង បរទេស ដោយមានហត្ថលេខារបស់គូភាគី
- សេចក្តីព្រាងកិច្ចព្រមព្រៀងដៃគូផ្តល់សេវាជាមួយក្រុមហ៊ុនធានារ៉ាប់រង ដែលជាដៃគូថ្មី
- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន បញ្ជាក់អំពីគុណវុឌ្ឍិរបស់បុគ្គលវិជ្ជាជីវៈ លក់ផលិតផលធានារ៉ាប់រងរបស់ក្រុមហ៊ុនធានារ៉ាប់រងជាដៃគូថ្មី រួមមាន បណ្ណចុះបញ្ជី ភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល និងវិញ្ញាបនបត្របញ្ចប់ការសិក្សាវគ្គបណ្តុះបណ្តាល ឯកទេសវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង ដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងជាដៃគូថ្មី។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ឆ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាត ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ២៥ .-**

រាល់ការបញ្ឈប់ការចាប់ដៃគូផ្តល់សេវាភ្នាក់ងារធានាទិញភាគហ៊ុនឬជើងសាធានាទិញភាគហ៊ុន ជាមួយក្រុមហ៊ុនធានាទិញភាគហ៊ុន ក្រុមហ៊ុនភ្នាក់ងារធានាទិញភាគហ៊ុន ក្រុមហ៊ុនជើងសាធានាទិញភាគហ៊ុន ឬសាខាក្រុមហ៊ុនជើងសាធានាទិញភាគហ៊ុនបរទេស ត្រូវជូនដំណឹងមក **ន.ឆ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៧ (ប្រាំពីរ) ថ្ងៃ ក្រោយបញ្ឈប់ការចាប់ដៃគូដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតជូនដំណឹងពីការបញ្ឈប់ការចាប់ដៃគូផ្តល់សេវាជាមួយក្រុមហ៊ុនធានាទិញភាគហ៊ុន ដោយបញ្ជាក់មូលហេតុច្បាស់លាស់
- ឯកសារបញ្ជាក់ពីការបញ្ឈប់ការចាប់ដៃគូផ្តល់សេវា រវាងក្រុមហ៊ុនធានាទិញភាគហ៊ុន និងក្រុមហ៊ុនភ្នាក់ងារធានាទិញភាគហ៊ុន ឬក្រុមហ៊ុនជើងសាធានាទិញភាគហ៊ុន ឬសាខាក្រុមហ៊ុនជើងសាធានាទិញភាគហ៊ុនបរទេស ដោយមានហត្ថលេខារបស់គូភាគី
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ជាច្បាប់ដើមឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

**ប្រការ២៦ .-**

ក្រុមហ៊ុនភ្នាក់ងារធានាទិញភាគហ៊ុន ក្រុមហ៊ុនជើងសាធានាទិញភាគហ៊ុន ឬសាខាក្រុមហ៊ុនជើងសាធានាទិញភាគហ៊ុនបរទេស ត្រូវជូនដំណឹងមក **ន.ឆ.ក.** ចំពោះរាល់ការបញ្ឈប់ឬការលាឈប់របស់បុគ្គលវិជ្ជាជីវៈតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ ឬបុគ្គលវិជ្ជាជីវៈលក់ផលិតផលធានាទិញភាគហ៊ុន ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីការបញ្ឈប់ឬការលាឈប់នោះ។

**ប្រការ២៧ .-**

រាល់ការផ្លាស់ប្តូរព័ត៌មានអំពីក្រុមហ៊ុនភ្នាក់ងារធានាទិញភាគហ៊ុន ក្រុមហ៊ុនជើងសាធានាទិញភាគហ៊ុន ឬសាខាក្រុមហ៊ុនជើងសាធានាទិញភាគហ៊ុនបរទេស មានជាអាទិ៍ នាមករណ៍ក្រុមហ៊ុន ម៉ាក ទីតាំងអាជីវកម្ម គេហទំព័រក្រុមហ៊ុន ម្ចាស់ភាគហ៊ុន សមាសភាពក្រុមប្រឹក្សាភិបាល អគ្គនាយក ឬការកែប្រែលក្ខខណ្ឌណាមួយក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ឆ.ក.**។ កាតព្វកិច្ចស្នើសុំការអនុញ្ញាតនេះ មិនអនុវត្តចំពោះក្រុមហ៊ុនភ្នាក់ងារធានាទិញភាគហ៊ុនដែលជាគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀតទេ។

**ន.ឆ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាត ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ)

ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

ឯកសារតម្រូវសម្រាប់ស្នើសុំការអនុញ្ញាតផ្លាស់ប្តូរព័ត៌មាន ឬកែប្រែលក្ខខណ្ឌណាមួយក្នុងលក្ខន្តិកៈក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ត្រូវកំណត់ដោយ **ន.ធ.ក.**។

**ប្រការ២៨ ._**

រាល់ការផ្លាស់ប្តូរព័ត៌មានអំពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ដែលជាភ្នាក់ងារធានារ៉ាប់រងមានជាអាទិ៍ នាមករណ៍ក្រុមហ៊ុន ម៉ាក ទីតាំងអាជីវកម្ម គេហទំព័រក្រុមហ៊ុន ម្ចាស់ភាគហ៊ុន សមាសភាពក្រុមប្រឹក្សាភិបាល អគ្គនាយក ឬការកែប្រែលក្ខខណ្ឌណាមួយក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវជូនដំណឹងមក **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីមានការផ្លាស់ប្តូរ។

**ប្រការ២៩ ._**

គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ដែលជាភ្នាក់ងារធានារ៉ាប់រងត្រូវជូនដំណឹងមក **ន.ធ.ក.** ចំពោះការផ្លាស់ប្តូរអ្នកគ្រប់គ្រងដំណើរការលក់ផលិតផលធានារ៉ាប់រង ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ថ្ងៃ បន្ទាប់ពីមានការផ្លាស់ប្តូរ ដោយភ្ជាប់ឯកសារតម្រូវដូចខាងក្រោម៖

- លិខិតជូនដំណឹងអំពីការផ្លាស់ប្តូរអ្នកគ្រប់គ្រងដំណើរការលក់ផលិតផលធានារ៉ាប់រង
- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុនបញ្ជាក់អំពីអ្នកគ្រប់គ្រងដំណើរការលក់ផលិតផលធានារ៉ាប់រងថ្មី រួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន និងកិច្ចសន្យាការងារ។

**ប្រការ៣០ ._**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង អាចផ្តល់សេវាភ្នាក់ងារធានារ៉ាប់រងជូនក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិតចំនួន ១ (មួយ) ក្រុមហ៊ុនធានារ៉ាប់រងទូទៅចំនួន ១ (មួយ) និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូចចំនួន ១ (មួយ) ប៉ុណ្ណោះ។

**ប្រការ៣១ ._**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ឬគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀត ដែលជាភ្នាក់ងារធានារ៉ាប់រង ត្រូវស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ក.** ចំពោះផ្លាស់ប្តូរបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ ឬបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងលក់ផលិតផលធានារ៉ាប់រង ដោយភ្ជាប់ឯកសារតម្រូវតាមករណីដូចខាងក្រោម៖

ក_ ចំពោះបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ

- លិខិតស្នើសុំការអនុញ្ញាតផ្លាស់ប្តូរបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ជាច្បាប់ដើមឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន
- បណ្ណចុះបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គល នៅ **ន.ធ.ក.** របស់បុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងដែលត្រូវតែងតាំងថ្មី ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

ខ. ចំពោះបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងលក់ផលិតផលធានារ៉ាប់រង

- លិខិតស្នើសុំការអនុញ្ញាតផ្លាស់ប្តូរបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងលក់ផលិតផលធានារ៉ាប់រង
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- បណ្ណចុះបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលនៅ **ន.ធ.ក.** និងវិញ្ញាបនបត្របញ្ចប់ការសិក្សា វគ្គបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង ដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងដៃគូ និង/ឬទីតាំងសាខាដែលត្រូវទទួលបន្ទុក របស់បុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងថ្មី ជាច្បាប់ថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាត ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

**ប្រការ៣២.-**

ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ត្រូវស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ក.** ចំពោះការផ្លាស់ប្តូរបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ ឬបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងលក់ផលិតផលធានារ៉ាប់រង ដោយភ្ជាប់ឯកសារតម្រូវតាមករណីដូចខាងក្រោម៖

ក. ចំពោះបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ

- លិខិតស្នើសុំការអនុញ្ញាតផ្លាស់ប្តូរបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ជាច្បាប់ដើមឬថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុន

- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុនបញ្ជាក់អំពីអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់បុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងដែលត្រូវតែងតាំងថ្មីរួមមាន អត្តសញ្ញាណបណ្ណឬលិខិតឆ្លងដែន ប្រវត្តិរូបសង្ខេប និងវិញ្ញាបនបត្រវិជ្ជាជីវៈជើងសាធានារ៉ាប់រងឬលិខិតបញ្ជាក់បទពិសោធការងារជើងសាធានារ៉ាប់រង។

ខ. ចំពោះបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងលក់ផលិតផលធានារ៉ាប់រង

- លិខិតស្នើសុំការអនុញ្ញាតផ្លាស់ប្តូរបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងលក់ផលិតផលធានា-រ៉ាប់រង។
- បង្កាន់ដៃបង់ប្រាក់កម្រៃសេវារដ្ឋបាល
- ឯកសារថតចម្លងដោយមានប្រថាប់ត្រាក្រុមហ៊ុនបញ្ជាក់អំពីគុណវុឌ្ឍិរបស់បុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងលក់ផលិតផលធានារ៉ាប់រងថ្មី រួមមាន បណ្ណចុះបញ្ជីភ្នាក់ងារធានារ៉ាប់រងជារូបវន្តបុគ្គលនៅ **ន.ធ.ក.** និងវិញ្ញាបនបត្របញ្ចប់ការសិក្សាវគ្គបណ្តុះបណ្តាលឯកទេសវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងដែលចេញដោយក្រុមហ៊ុនធានារ៉ាប់រងដៃគូ។

ក្រោយពីពិនិត្យ និងវាយតម្លៃលើឯកសារតម្រូវខាងលើ **ន.ធ.ក.** មានសិទ្ធិសម្រេចផ្តល់លិខិតអនុញ្ញាត ឬបដិសេធលើការស្នើសុំ ក្នុងរយៈពេល ២០ (ម្ភៃ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទទទួលបានសំណុំឯកសារគ្រប់គ្រាន់។

## ជំពូកទី៥
## កម្រៃសេវារដ្ឋបាល និងកម្រៃអាជ្ញាបណ្ណ

**ប្រការ៣៣ .-**

រាល់កម្រៃអាជ្ញាបណ្ណ កម្រៃសេវារដ្ឋបាល និងប្រាក់ផាកពិន័យ ត្រូវបង់ចូលគណនីរបស់ **ន.ធ.ក.**។

### ផ្នែកទី១
### កម្រៃសេវារដ្ឋបាល

**ប្រការ៣៤ .-**

បុគ្គលស្នើសុំ ត្រូវបង់កម្រៃសេវារដ្ឋបាលដូចខាងក្រោម៖

- សេវាពិនិត្យសំណុំឯកសារស្នើសុំការអនុញ្ញាតជាគោលការណ៍ប្រកបអាជីវកម្មភ្នាក់ងារធានារ៉ាប់រង ឬអាជីវកម្មជើងសាធានារ៉ាប់រង ជាក្រុមហ៊ុនឬសាខាក្រុមហ៊ុនបរទេស ចំនួន ១ ០០០ ០០០ (មួយលាន) រៀល
- សេវាពិនិត្យសំណុំឯកសារស្នើសុំអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ចំនួន ១ ០០០ ០០០ (មួយលាន) រៀល។

**ប្រការ៣៥.-**

បុគ្គលស្នើសុំ ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារស្នើសុំការអនុញ្ញាតបន្តសុពលភាពអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រង ចំនួន ១ ០០០ ០០០ (មួយលាន) រៀល។

**ប្រការ៣៦.-**

បុគ្គលស្នើសុំ ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារស្នើសុំការអនុញ្ញាតចាប់ដៃគូ ឬផ្លាស់ប្តូរដៃគូផ្តល់សេវាភ្នាក់ងារធានារ៉ាប់រងឬជើងសាធានារ៉ាប់រង ជាមួយក្រុមហ៊ុនធានារ៉ាប់រង ចំនួន ៨០០ ០០០(ប្រាំបីរយពាន់) រៀល។

**ប្រការ៣៧.-**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារស្នើសុំការអនុញ្ញាតផ្លាស់ប្តូរព័ត៌មាន ឬកែប្រែលក្ខខណ្ឌណាមួយក្នុងលក្ខន្តិកៈក្រុមហ៊ុន ដូចមានចែងក្នុងប្រការ ២៧ នៃប្រកាសនេះ ចំនួន ៨០០ ០០០(ប្រាំបីរយពាន់) រៀល។

**ប្រការ៣៨.-**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ត្រូវបង់កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារស្នើសុំការអនុញ្ញាតផ្លាស់ប្តូរបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង ឬបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រង ដូចខាងក្រោម ៖

ក. ចំពោះបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងឬបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ
- បុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ ចំនួន ៤០០ ០០០ (បួនរយពាន់) រៀល ក្នុង ១ (មួយ) រូប
- បុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងតាមលក្ខខណ្ឌតម្រូវនៃអាជ្ញាបណ្ណ ចំនួន ២ ០០០ ០០០ (ពីរលាន) រៀល ក្នុង ១ (មួយ) រូប។

ខ. ចំពោះបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង ឬបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងលក់ផលិតផលធានារ៉ាប់រង
- បុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងលក់ផលិតផលធានារ៉ាប់រង ចំនួន ២០០ ០០០ (ពីររយពាន់) រៀល ក្នុង ១ (មួយ) លើក
- បុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រងលក់ផលិតផលធានារ៉ាប់រង ចំនួន ១ ០០០ ០០០ (មួយលាន) រៀល ក្នុង ១ (មួយ) លើក។

**ប្រការ៣៩.-**

កម្រៃសេវារដ្ឋបាលសម្រាប់សេវាពិនិត្យសំណុំឯកសារអនុលោមតាមខ្លឹមសារនៃប្រកាសនេះ មិនត្រូវប្រគល់ឱ្យបុគ្គលស្នើសុំឬក្រុមហ៊ុនវិញឡើយ ទោះបីជាការស្នើសុំត្រូវបដិសេធក៏ដោយ។

## ផ្នែកទី២

## កម្រៃអាជ្ញាបណ្ណ

**ប្រការ៤០.-**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ត្រូវបង់កម្រៃអាជ្ញាបណ្ណ នៅពេលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណនិងនៅរៀងរាល់ពេលដាក់ពាក្យស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ ដូចខាងក្រោម៖

- កម្រៃអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រងជាក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ចំនួន ៣ ០០០ ០០០ (បីលាន)រៀល
- កម្រៃអាជ្ញាបណ្ណអាជីវកម្មអន្តរការីធានារ៉ាប់រងជាក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ចំនួន ២០ ០០០ ០០០ (ម្ភៃលាន)រៀល។

## ជំពូកទី៦

## ទោសប្បញ្ញត្តិ

**ប្រការ៤១.-**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ទាំងឡាយណា ដែលមិនអនុវត្តតាមបទប្បញ្ញត្តិនៃប្រកាសនេះ ត្រូវទទួលវិធានការរដ្ឋបាលពី **ន.ធ.ក.** ដូចខាងក្រោម៖

- ការព្រមាន
- ការដឹកនាំកែតម្រង់
- ការដាក់កំហិតលើសកម្មភាពអាជីវកម្ម
- ការដាក់កំហិតលើអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត
- ការដកហូតអាជ្ញាបណ្ណ ឬវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត។

**ប្រការ៤២.-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់

ពី ៥០០ ០០០ (ប្រាំរយពាន់) រៀល ទៅ ២៥ ០០០ ០០០(ម្ភៃប្រាំលាន) រៀល ដោយ **ន.ឥ.ក.** និងត្រូវស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណជាបន្ទាន់ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យចំពោះក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសទាំងឡាយណា ដែលមិនស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណឱ្យបានមុនរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ នៃកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ដូចមានចែងក្នុងប្រការ១០ និងប្រការ១៨ នៃប្រកាសនេះ។

**ប្រការ៤៣.-**

ត្រូវទទួលទោសតាមច្បាប់ស្ដីពីការធានារ៉ាប់រង និងត្រូវស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណជាបន្ទាន់ក្នុងរយៈពេល ៣០(សាមសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណនោះ ចំពោះក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ទាំងឡាយណាដែលមិនបានស្នើសុំបន្តសុពលភាពអាជ្ញាបណ្ណ បន្ទាប់ពីកាលបរិច្ឆេទផុតសុពលភាពអាជ្ញាបណ្ណ ដូចមានចែងក្នុងប្រការ១១ និងប្រការ១៩ នៃប្រកាសនេះ។

**ប្រការ៤៤.-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ១០ ០០០ ០០០(ដប់លាន) រៀល ដោយ **ន.ឥ.ក.** និងត្រូវស្នើសុំការអនុញ្ញាតមក **ន.ឥ.ក.** ជាបន្ទាន់ក្នុងរយៈពេល ១០(ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យចំពោះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀតដែលជាក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងទាំងឡាយណាដែលដំណើរការអាជីវកម្មភ្នាក់ងារធានារ៉ាប់រងតាមសាខាក្នុងស្រុក ដោយមិនបានស្នើសុំការអនុញ្ញាតមក **ន.ឥ.ក.** ដូចមានចែងក្នុងប្រការ១២ នៃប្រកាសនេះ។

**ប្រការ៤៥.-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ឥ.ក.** និងត្រូវបន្តសុពលភាពវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈ និងជូនដំណឹងមក **ន.ឥ.ក.** ជាបន្ទាន់ក្នុងរយៈពេល ១០(ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យ ចំពោះក្រុមហ៊ុនជើងសាធានារ៉ាប់រងឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសទាំងឡាយណា ដែលមិនបានបន្តសុពលភាពវិញ្ញាបនបត្រធានារ៉ាប់រងភារៈទទួលខុសត្រូវវិជ្ជាជីវៈជើងសាធានារ៉ាប់រងទាន់ពេលវេលា និងមិនបានជូនដំណឹងមក **ន.ឥ.ក.** តាមកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងប្រការ២១ នៃប្រកាសនេះ។

**ប្រការ៤៦ .-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន) រៀល ទៅ១០០ ០០០ ០០០(មួយរយលាន) រៀល ដោយ **ន.ធ.ក.** និងត្រូវបញ្ឈប់ការចាប់ដៃគូផ្តល់សេវាជាបន្ទាន់ ចំពោះក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសទាំងឡាយណា ដែលចាប់ដៃគូផ្តល់សេវាភ្នាក់ងារធានារ៉ាប់រងឬជើងសាធានារ៉ាប់រង ជាមួយក្រុមហ៊ុនធានារ៉ាប់រងដែលមិនមានអាជ្ញាបណ្ណអាជីវកម្មធានារ៉ាប់រងក្នុងព្រះរាជាណាចក្រកម្ពុជា ដូចមានចែងក្នុងប្រការ២៣ នៃប្រកាសនេះ។

**ប្រការ៤៧ .-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ដោយ **ន.ធ.ក.** និងត្រូវស្នើសុំការអនុញ្ញាតមក **ន.ធ.ក.** ជាបន្ទាន់ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យ ចំពោះក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសទាំងឡាយណា ដែលចាប់ដៃគូឬផ្លាស់ប្តូរដៃគូផ្តល់សេវាភ្នាក់ងារធានារ៉ាប់រង ឬជើងសាធានារ៉ាប់រង ជាមួយក្រុមហ៊ុនធានារ៉ាប់រងដោយមិនបានស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ក.** ដូចមានចែងក្នុងប្រការ២៤ នៃប្រកាសនេះ។

**ប្រការ៤៨ .-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន) រៀល ទៅ ១០ ០០០ ០០០(ដប់លាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសទាំងឡាយណា ដែលបញ្ឈប់ការចាប់ដៃគូផ្តល់សេវាភ្នាក់ងារធានារ៉ាប់រងឬជើងសាធានារ៉ាប់រងជាមួយក្រុមហ៊ុនធានារ៉ាប់រង ដោយមិនបានជូនដំណឹងមក **ន.ធ.ក.** តាមកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងប្រការ២៥ នៃប្រកាសនេះ។

**ប្រការ៤៩ .-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ ៥០០ ០០០ (ប្រាំរយពាន់) ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសទាំងឡាយណា ដែលមិនបានជូនដំណឹងមក **ន.ធ.ក.** នៅពេលបញ្ឈប់ ឬមានការលាឈប់របស់បុគ្គល

វិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រងឬបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រង តាមកាលបរិច្ឆេទកំណត់ដូចមានចែងក្នុងប្រការ២៦ នៃប្រកាសនេះ។

**ប្រការ៥០ ._**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ១ ០០០ ០០០(មួយលាន) ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ធ.ក.** និងត្រូវស្នើសុំការអនុញ្ញាតមក **ន.ធ.ក.** ជាបន្ទាន់ក្នុងរយៈពេល ១០(ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យ ចំពោះក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសទាំងឡាយណា ដែលបានផ្លាស់ប្តូរព័ត៌មាន ឬកែប្រែលក្ខខណ្ឌណាមួយក្នុងលក្ខន្តិកៈក្រុមហ៊ុន ដោយមិនបានស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ក.** ដូចមានចែងក្នុងប្រការ២៧ នៃប្រកាសនេះ។

**ប្រការ៥១ ._**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ៥០០ ០០០(ប្រាំរយពាន់) រៀល ទៅ ៥ ០០០ ០០០(ប្រាំលាន) រៀល ដោយ **ន.ធ.ក.** ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀតដែលជាភ្នាក់ងារធានារ៉ាប់រង ដែលផ្លាស់ប្តូរព័ត៌មាន ឬកែប្រែលក្ខខណ្ឌណាមួយក្នុងលក្ខន្តិកៈក្រុមហ៊ុន ដោយមិនបានជូនដំណឹងមក **ន.ធ.ក.** តាមការកំណត់ដូចមានចែងក្នុងប្រការ២៨ នៃប្រកាសនេះ។

**ប្រការ៥២ ._**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ៥០០ ០០០(ប្រាំរយពាន់) រៀល ទៅ ៥ ០០០ ០០០(ប្រាំលាន) រៀល ដោយ **ន.ធ.ក.** ចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀតដែលជាភ្នាក់ងារធានារ៉ាប់រង ដែលផ្លាស់ប្តូរអ្នកគ្រប់គ្រងដំណើរការលក់ផលិតផលធានារ៉ាប់រង ដោយមិនបានជូនដំណឹងមក **ន.ធ.ក.** តាមការកំណត់ដូចមានចែងក្នុងប្រការ២៩ នៃប្រកាសនេះ។

**ប្រការ៥៣ ._**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ៥ ០០០ ០០០(ប្រាំលាន) រៀល ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ធ.ក.** ចំពោះក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងទាំងឡាយណា ដែលចាប់ដៃគូជាមួយក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុន

ធានារ៉ាប់រងទូទៅ និងក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច លើសចំនួនកំណត់ដូចមានចែងក្នុងប្រការ៣០ នៃប្រកាសនេះ។

**ប្រការ៥៤ .-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ៥០០ ០០០(ប្រាំរយពាន់) រៀល ទៅ ៥ ០០០ ០០០(ប្រាំលាន) រៀល ដោយ **ន.ធ.ក.** និងត្រូវស្នើសុំការអនុញ្ញាតមក **ន.ធ.ក.** ជាបន្ទាន់ក្នុងរយៈពេល ១០(ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យ ចំពោះក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង និងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុឬនីតិបុគ្គលប្រតិស្រុតផ្សេងទៀតដែលជាភ្នាក់ងារធានារ៉ាប់រង ដែលតែងតាំងឬផ្លាស់ប្តូរបុគ្គលវិជ្ជាជីវៈភ្នាក់ងារធានារ៉ាប់រង ដោយមិនបានស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ក.** ដូចមានចែងក្នុងប្រការ៣១ នៃប្រកាសនេះ។

**ប្រការ៥៥ .-**

ត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ និង/ឬត្រូវផាកពិន័យជាប្រាក់ពី ២ ០០០ ០០០(ពីរលាន) ទៅ ២០ ០០០ ០០០(ម្ភៃលាន) រៀល ដោយ **ន.ធ.ក.** និងត្រូវស្នើសុំការអនុញ្ញាតមក **ន.ធ.ក.** ជាបន្ទាន់ក្នុងរយៈពេល ១០(ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលវិធានការរដ្ឋបាល និង/ឬកាលបរិច្ឆេទចេញដីកាផាកពិន័យ ចំពោះក្រុមហ៊ុនជើងសាធានារ៉ាប់រងឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសទាំងឡាយណា ដែលតែងតាំងឬផ្លាស់ប្តូរបុគ្គលវិជ្ជាជីវៈជើងសាធានារ៉ាប់រង ដោយមិនបានស្នើសុំការអនុញ្ញាតជាមុនមក **ន.ធ.ក.** ដូចមានចែងក្នុងប្រការ៣២ នៃប្រកាសនេះ។

**ប្រការ៥៦ .-**

ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេស ដែលធ្លាប់ទទួលការផាកពិន័យអន្តរការណ៍ម្តងហើយ ប៉ុន្តែនៅតែបន្តប្រព្រឹត្តអំពើល្មើសដដែល ត្រូវទទួលការផាកពិន័យជាប្រាក់ចំនួនទ្វេដងនៃទឹកប្រាក់ផាកពិន័យលើកមុន និង/ឬត្រូវទទួលវិធានការរដ្ឋបាលដូចមានចែងក្នុងប្រការ៤១ នៃប្រកាសនេះ។

**ប្រការ៥៧ .-**

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី១ (បទប្បញ្ញត្តិទូទៅ) និងជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី៣ (ការបង្ខំដល់រូបកាយ) នៃគន្ថីទី៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត ក្នុងករណីដែលសេចក្តីសម្រេចអំពីការផាកពិន័យបានចូលជាស្ថាពរ។

**ប្រការ៥៨.-**

បែបបទ និងនីតិវិធីនៃការចាត់វិធានការរដ្ឋបាល និងការដាក់ពិន័យដូចមានចែកក្នុងជំពូកនេះ ត្រូវកំណត់ដោយ **ន.ធ.ក.**។

**ប្រការ៥៩.-**

បុគ្គលដែលរងឥទ្ធិពលដោយផ្ទាល់ពីសេចក្តីសម្រេចរបស់និយ័តករ ដូចមានចែងក្នុងជំពូកនេះ អាចប្តឹងតវ៉ាតាមនីតិវិធីដូចមានចែងក្នុងច្បាប់ស្តីពីការធានារ៉ាប់រង។

**ប្រការ៦០.-**

វិធានការរដ្ឋបាលនិងការដាក់ពិន័យដូចមានចែងក្នុងជំពូកនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី៧

## អន្តរប្បញ្ញត្តិ

**ប្រការ៦១.-**

អាជ្ញាបណ្ណដែលបានផ្តល់ជូនក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រង ក្រុមហ៊ុនជើងសាធានារ៉ាប់រង ឬសាខាក្រុមហ៊ុនជើងសាធានារ៉ាប់រងបរទេសទាំងអស់ អនុលោមតាមប្រកាសលេខ ៨៦៥ សហវ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីការចេញអាជ្ញាបណ្ណធានារ៉ាប់រងជូនភ្នាក់ងារធានារ៉ាប់រង ជើងសាធានារ៉ាប់រង និងក្រុមហ៊ុនត្រួតពិនិត្យហានិភ័យធានារ៉ាប់រង និង/ឬ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ត្រូវបន្តសុពលភាពរហូតដល់ផុតកាលកំណត់នៃអាជ្ញាបណ្ណ ទោះជាប្រកាសនេះចាប់ផ្តើមអនុវត្តក៏ដោយ។

**ប្រការ៦២.-**

ក្នុងអំឡុងពេល ១២ (ដប់ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទអនុវត្តប្រកាសនេះ ក្រុមហ៊ុនភ្នាក់ងារធានារ៉ាប់រងក្រុមហ៊ុនជើងសាធានារ៉ាប់រងទាំងឡាយដែលកំពុងប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញដើមទុនអប្បបរមាឱ្យគ្រប់ចំនួន ដូចមានចែងក្នុងប្រការ៥ និងប្រការ១៥ នៃប្រកាសនេះ។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ៦៣.-**

អគ្គនាយកនៃ **ន.ធ.ក.** អាចចេញគោលការណ៍ណែនាំ អនុលោមតាមច្បាប់ស្តីពីការធានារ៉ាប់រង អនុក្រឹត្យស្តីពីការធានារ៉ាប់រង និងប្រកាសនេះដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះ។

**ប្រការ៦៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦៥ .-**

អគ្គនាយកនៃ **ន.ឆ.ភ.** ប្រធាននាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណនិងកិច្ចការគតិយុត្ត គ្រប់ប្រធាននាយកដ្ឋានស្ថិតក្រោមចំណុះ **ន.ឆ.ភ.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៦ រោច ខែ មិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ខែ ធ្នូ ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- និយ័តករទូរគមនាគមន៍កម្ពុជា
- និយ័តករគណនេយ្យនិងសវនកម្ម
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ឯកឧត្តម លោកជំទាវជាអនុប្រធាន និងសមាជិកក្រុមប្រឹក្សា-អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

  "ដើម្បីជូនជ្រាប"
- ដូចប្រការ៦៥

  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ